# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2013

**ធនាគារភូមិ (ខេមបូឌា) អិលធីឌី**

**របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2013**

**មាតិកា**


| | **ទំព័រ** |
|---|---|
| របាយការណ៍ក្រុមប្រឹក្សាភិបាល | 1 - 3 |
| របាយការណ៍សវនករឯករាជ | 4 - 5 |
| តារាងតុល្យការ | 6 |
| របាយការណ៍លទ្ធផល | 7 |
| របាយការណ៍បម្រែបម្រួលមូលធន | 8 |
| របាយការណ៍លំហូរសាច់ប្រាក់ | 9 |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ | 10 - 47 |
| ឧបសម្ព័ន្ធ ៖ កំណត់សម្គាល់ស្តីពីការអនុវត្តតាមប្រកាសរបស់ធនាគារកណ្តាល* | i - viii |


*ឧបសម្ព័ន្ធមិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មនេះទេ។

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ភូមិ (ខេមបូឌា) អិលធីឌី (ហៅកាត់ថា"ក្រុមហ៊ុន") មានសេចក្តីសោមនស្ស ក្នុងការដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មហើយ របស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2013។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុដល់ប្រជាជននៅជនបទក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈទីស្នាក់ការកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងការិយាល័យថ្នាក់ខេត្តផ្សេងៗមួយចំនួនទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលដៅរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុដែលមានភាពជឿទុកចិត្ត និងដែលអាចទទួលយកបានដល់សហគ្រិនខ្នាតតូច។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2013 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផល នៅលើទំព័រទី 7 នៃរបាយការណ៍ហិរញ្ញវត្ថុ។

នៅថ្ងៃទី11 ខែមេសា ឆ្នាំ2013 ភាគលាភចំនួន 886 លានរៀល ត្រូវបានប្រកាស និងបានបង់ នៅថ្ងៃទី20 ខែឧសភា ឆ្នាំ2013 នៃប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2012 (ឆ្នាំ 2012 ៖ 586 លានរៀល ពីប្រាក់ចំណេញសុទ្ធក្នុងឆ្នាំ2011)។

## ឥណទានអាក្រក់ និងឥណទានសង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ពាក់ព័ន្ធទៅនឹងការជម្រះឥណទានអាក្រក់ចេញពីបញ្ជី ឬការធ្វើសំវិធានធនឥណទានអាក្រក់និងសង្ស័យ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទានអាក្រក់ទាំងអស់ដែលបានដឹង ត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនយ៉ាងពេញលេញ សម្រាប់ឥណទានអាក្រក់ និងសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលនាំឲ្យចំនួនសំវិធានធនឥណទានអាក្រក់និងសង្ស័យ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងឡាយដែលទំនងជាមិនអាចបង្វិលមកវិញបាន នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ទៅតាមតម្លៃនៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកត់ត្រាបន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថាអាចនឹងបង្វិលមកវិញបាន។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងអំពីហេតុការណ៍ណាមួយ ដែលអាចបណ្តាលឲ្យតម្លៃទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ពុំត្រឹមត្រូវជាសារវន្តនោះទេ។



E-mail : tpcho@tpc.com.kh
Tel: (855) 23 220 641 - Fax : (855) 23 220 642
#94, Street 360, Sangkat Boeung Keng Kang III,
Khan Chamkarmon, Phnom Penh, Cambodia

### បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន ៖

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក និង

ខ. បំណុលយថាភាពណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំមក ក្រៅពីបំណុលផ្សេងៗ នៅក្នុងដំណើរការអាជីវកម្មធម្មតានោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុនបានក្លាយជាការបង្ខំឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងអំឡុងពេល 12ខែ បន្ទាប់ពីដំណាច់ឆ្នាំដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់ពេលកំណត់សងនោះទេ។

### ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយដែលមិនបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

### ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2013 មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងដំណាច់ឆ្នាំនេះ រហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍ មិនមានខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយដែលអាចមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្នុងឆ្នាំដែលរបាយការណ៍នេះត្រូវបានធ្វើឡើងនោះទេ។

### ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលនៅបម្រើការក្នុងអំឡុងឆ្នាំ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម ៖

| | |
|---|---|
| Mrs. Fernanda Pecanha Lacerda De Lima | ប្រធានក្រុមប្រឹក្សាភិបាល |
| Mr. Chandula Palith Abeywickrema | អភិបាល (មិនប្រតិបត្តិ) |
| Mr. Christophe Forsinetti | អភិបាល (មិនប្រតិបត្តិ) |
| Mrs. Jessica Moffett-Rose | អភិបាល (មិនប្រតិបត្តិ) (បានលាលែងពីតំណែង នៅថ្ងៃទី01 ខែកុម្ភៈ ឆ្នាំ2013 |
| Mr. Hans Michael Theodor Moormann | អភិបាល (មិនប្រតិបត្តិ) (បានតែងតាំង នៅថ្ងៃទី01 ខែកុម្ភៈ ឆ្នាំ2013) |
| Mr. Vann Saroeun | អភិបាល (មិនប្រតិបត្តិ) (បានតែងតាំង នៅថ្ងៃទី01 ខែកុម្ភៈ ឆ្នាំ2013) |

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល លើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2013 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលត្រូវ ៖

- i) អនុវត្តគោលការណ៍គណនេយ្យសមស្របដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះឱ្យមានសង្គតភាព។
- ii) អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន ដែលអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជានិងគោលការណ៍ណែនាំរបស់ធនាគារកណ្តាល ហើយប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញឱ្យមានភាពពិតនឹងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនោះត្រូវបានបង្ហាញពន្យល់ និងកំណត់ចំនួនទឹកប្រាក់ឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
- iii) រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។
- iv) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីសន្មតសមរម្យថា ក្រុមហ៊ុននឹងមិនអាចបន្តកិច្ចប្រតិបត្តិការអាជីវកម្មនា ពេលខាងមុខដ៏ខ្លី និង
- v) កំណត់គោលនយោបាយទូទៅសម្រាប់ក្រុមហ៊ុន ផ្តល់សច្ចានុម័តលើរាល់សេចក្តីសម្រេចចិត្ត និងសកម្មភាពរបស់ក្រុមប្រឹក្សាភិបាល ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការ និងលទ្ធផលរបស់ក្រុមហ៊ុន ហើយត្រូវធានាថាផលប៉ះពាល់ទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមតម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលធានាអះអាងថា របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយ បានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ 2013 និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និង គោលការណ៍ណែនាំរបស់ធនាគារកណ្តាល។

ចុះហត្ថលេខាតាងនាមឲ្យក្រុមប្រឹក្សាភិបាល

ធនាគារ ... (ខេមបូឌា) លីមីធីត THANAKAN PHUM (CAMBODIA) LTD.

លោក Vann Saroeun
អភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី 27 ខែកុម្ភៈ ឆ្នាំ2014

pwc

**របាយការណ៍សវនករឯករាជ**
**ជូនភាគទុនិក ធនាគារភូមិ (ខេមបូឌា) អិលធីឌី**

យើងខ្ញុំបានធ្វើសវនកម្ម ទៅលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយរបស់ ធនាគារភូមិ (ខេមបូឌា) អិលធីឌី (ហៅកាត់ថា "ក្រុមហ៊ុន") រួមមានតារាងតុល្យការ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2013 របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធនភាគទុនិក និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ព្រមទាំងកំណត់សម្គាល់ រួមមានសេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់ដទៃទៀត។

*ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ*

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារកណ្តាល និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

*ការទទួលខុសត្រូវរបស់សវនករ*

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ដោយផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា។ ស្តង់ដារទាំងនោះតម្រូវឱ្យយើងខ្ញុំប្រតិបត្តិតាមក្រមសីលធម៌ ធ្វើផែនការ និងធ្វើសវនកម្មដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុពុំមានលក្ខណៈខុសឆ្គងជាសារវន្ត។

ការធ្វើសវនកម្មរួមមានការអនុវត្តនីតិវិធីដើម្បីទទួលបាននូវភស្តុតាងសវនកម្ម អំពីចំនួនទឹកប្រាក់ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ការជ្រើសរើសនីតិវិធីទាំងនេះគឺអាស្រ័យលើការវិនិច្ឆ័យរបស់សវនករ រាប់ទាំងការវាយតម្លៃលើហានិភ័យនៃភាពខុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង។ ក្នុងការវាយតម្លៃហានិភ័យទាំងនោះ សវនករបានពិចារណាទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាពដែលទាក់ទងទៅនឹងការរៀបចំ និងការបង្ហាញយ៉ាងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដើម្បីរៀបចំនូវនីតិវិធីសវនកម្ម ដែលមានលក្ខណៈសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ ប៉ុន្តែពុំមានគោលបំណងបញ្ចេញមតិទៅលើប្រសិទ្ធភាព នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាពនោះទេ។ សវនកម្មក៏រួម បញ្ចូលទាំងការវាយតម្លៃនូវភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យដែលធ្វើឡើងដោយគណៈគ្រប់គ្រង ក៏ដូចជាការវាយតម្លៃលើការបង្ហាញជាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងទទួលបាន គឺមានលក្ខណៈគ្រប់គ្រាន់ និង ត្រឹមត្រូវ ដែលជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

*PricewaterhouseCoopers (Cambodia) Ltd.*
*35 Sihanouk Boulevard, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh, Cambodia*
*T: +855 (0)23 218 086, F: +855(0)23 211 594, www.pwc.com/kh*

*មតិយោបល់*

តាមទស្សនៈរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយ បានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2013 និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារកណ្តាល។

ជ. PricewaterhouseCoopers (Cambodia) Ltd.

ព្រះរាជាណាចក្រកម្ពុជា
ប្រាយវ៉តធើរ
ហោសឃើស(ខេមបូឌា)
PricewaterhouseCoopers
(Cambodia) Ltd.
ទីស្នាក់ការរាជធានីភ្នំពេញ

គុយ លីម
នាយក

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទៈ ថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2014

# តារាងតុល្យការ
## គិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2013

| | កំណត់ | 2013 | | 2012 | |
|---|---|---|---|---|---|
| | សម្គាល់ | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 4 | 1,324,774 | 331,608 | 939,095 | 235,068 |
| សមតុល្យនៅធនាគារកណ្តាល | 5 | 18,589,131 | 4,653,099 | 12,577,176 | 3,148,229 |
| សមតុល្យនៅធនាគារផ្សេងៗ | 6 | 48,917,665 | 12,244,722 | 32,365,810 | 8,101,579 |
| ឥណទានអតិថិជន | 7 | 298,965,299 | 74,834,868 | 192,985,045 | 48,306,645 |
| ការវិនិយោគ | | 59,925 | 15,000 | 59,925 | 15,000 |
| ទ្រព្យសកម្មផ្សេងៗ | 8 | 7,979,127 | 1,997,279 | 5,206,044 | 1,303,140 |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | 9 | 3,210,723 | 803,685 | 2,391,649 | 598,661 |
| ទ្រព្យសកម្មអរូបី | 10 | 9,285 | 2,324 | 18,570 | 4,648 |
| ពន្ធពន្យារទ្រព្យសកម្ម | 11 | 570,258 | 142,743 | 200,693 | 50,236 |
| **ទ្រព្យសកម្មសរុប** | | **379,626,187** | **95,025,328** | **246,744,007** | **61,763,206** |
| **បំណុល និងមូលធនភាគទុនិក** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើកាតព្វកិច្ច | 12 | - | - | 155,478 | 38,918 |
| ឥណទានវិបារូបន៍ | 13 | 1,922,559 | 481,241 | - | - |
| ប្រាក់កម្ចី | 14 | 295,963,017 | 74,083,358 | 191,839,632 | 48,019,933 |
| បំណុលផ្សេងៗ | 15 | 9,442,674 | 2,363,623 | 8,069,777 | 2,019,969 |
| ចំណូលនៃប្រាក់ជំនួយពន្យារ | | 6,876 | 1,722 | 9,168 | 2,295 |
| បំណុលពន្ធលើប្រាក់ចំណេញ | 11 | 4,022,431 | 1,006,866 | 1,759,349 | 440,388 |
| **បំណុលសរុប** | | **311,357,557** | **77,936,810** | **201,833,404** | **50,521,503** |
| **មូលធនភាគទុនិក** | | | | | |
| ដើមទុន | 16 | 23,368,200 | 5,849,362 | 12,176,400 | 3,047,910 |
| ទុនបម្រុងផ្សេងៗ | | 3,107,877 | 777,941 | 2,531,770 | 633,735 |
| អនុបំណុល | | - | - | 4,064,000 | 1,017,272 |
| ចំណេញរក្សាទុក | | 41,792,553 | 10,461,215 | 26,138,433 | 6,542,786 |
| **មូលធនភាគទុនិកសរុប** | | **68,268,630** | **17,088,518** | **44,910,603** | **11,241,703** |
| **បំណុល និងមូលធនភាគទុនិកសរុប** | | **379,626,187** | **95,025,328** | **246,744,007** | **61,763,206** |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី 10 ដល់ទំព័រទី 47 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍លទ្ធផល
# សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2013

| | កំណត់ | 2013 | | 2012 | |
|---|---|---|---|---|---|
| | សម្គាល់ | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណូលការប្រាក់ | 17 | 76,235,779 | 19,082,798 | 50,002,257 | 12,516,210 |
| ចំណាយការប្រាក់ | 18 | (22,497,128) | (5,631,321) | (16,382,217) | (4,100,680) |
| **ចំណូលការប្រាក់សុទ្ធ** | | **53,738,651** | **13,451,477** | **33,620,040** | **8,415,530** |
| សំវិធានធនឥណទានអាក្រក់និងសង្ស័យ | 7 | (320,251) | (80,163) | (411,695) | (103,053) |
| **ចំណូលការប្រាក់សុទ្ធក្រោយសំវិធានធន បំណុលអាក្រកក និងសង្ស័យ** | | **53,418,400** | **13,371,314** | **33,208,345** | **8,312,477** |
| ចំណូលផ្សេងៗ | 19 | 885,829 | 221,734 | 628,070 | 157,214 |
| ចំណាយកម្រៃជើងសារ | 20 | (1,159,147) | (290,149) | (690,790) | (172,914) |
| ចំណាយបុគ្គលិក | 21 | (20,824,702) | (5,212,691) | (13,824,745) | (3,460,512) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | | (1,353,129) | (338,706) | (1,039,706) | (260,252) |
| ចំណាយទូទៅនិងចំណាយរដ្ឋបាល | 22 | (9,245,441) | (2,314,253) | (6,985,662) | (1,748,601) |
| ខាតពីការប្តូររូបិយប័ណ្ណបរទេស | | (256,506) | (64,207) | (161,895) | (40,524) |
| | | **21,465,304** | **5,373,042** | **11,133,617** | **2,786,888** |
| **ចំណេញប្រតិបត្តិការ** | | | | | |
| ចំណូលបានពីជំនួយ | | 2,292 | 574 | 3,056 | 765 |
| **ចំណេញមុនបង់ពន្ធ** | | **21,467,596** | **5,373,616** | **11,136,673** | **2,787,653** |
| ចំណាយពន្ធលើប្រាក់ចំណេញ | 11 | (4,350,927) | (1,089,093) | (2,269,139) | (567,995) |
| **ចំណេញសុទ្ធក្នុងឆ្នាំ** | | **17,116,669** | **4,284,523** | **8,867,534** | **2,219,658** |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី 10 ដល់ទំព័រទី 47 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2013

| | កំណត់សម្គាល់ | ដើមទុន ពាន់រៀល | ទុនបម្រុង ពាន់រៀល | អនុបំណុល ពាន់រៀល | ចំណេញរក្សាទុក ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2012** | | 6,176,400 | 1,955,663 | - | 24,433,764 | 32,565,827 |
| ដើមទុនបន្ថែម | | 6,000,000 | - | - | (6,000,000) | - |
| ភាគលាភបានបង់ | 23 | - | - | - | (586,758) | (586,758) |
| ផ្ទេរទៅដើមទុនបម្រុង | | - | 576,107 | - | (576,107) | - |
| ចំណេញសុទ្ធក្នុងឆ្នាំ | | - | - | - | 8,867,534 | 8,867,534 |
| អនុបំណុល | | - | - | 4,064,000 | - | 4,064,000 |
| សមតុល្យគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2012 | | **12,176,400** | **2,531,770** | **4,064,000** | **26,138,433** | **44,910,603** |
| សមមូលជាដុល្លារអាមេរិក | | **3,047,910** | **633,735** | **1,017,272** | **6,542,786** | **11,241,703** |
| | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2013 | | 12,176,400 | 2,531,770 | 4,064,000 | 26,138,433 | 44,910,603 |
| ដើមទុនបន្ថែម | | 7,127,800 | - | - | - | 7,127,800 |
| ការផ្ទេរអនុបំណុលទៅក្នុងដើមទុន | | 4,064,000 | - | (4,064,000) | - | - |
| ភាគលាភបានបង់ | 23 | - | - | - | (886,442) | (886,442) |
| ផ្ទេរទៅដើមទុនបម្រុង | | - | 576,107 | - | (576,107) | - |
| ចំណេញសុទ្ធក្នុងឆ្នាំ | | - | - | - | 17,116,669 | 17,116,669 |
| សមតុល្យគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2013 | | **23,368,200** | **3,107,877** | **-** | **41,792,553** | **68,268,630** |
| សមមូលជាដុល្លារអាមេរិក | | **5,849,362** | **777,941** | **-** | **10,461,215** | **17,088,518** |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី 10 ដល់ទំព័រទី 47 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ធនាគារភូមិ (ខេមបូឌា) អិលធីឌី

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2013

| | កំណត់ | 2013 | | 2012 | |
|---|---|---|---|---|---|
| | សម្គាល់ | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញមុនបង់ពន្ធ | | 21,467,596 | 5,373,616 | 11,136,673 | 2,787,653 |
| *និយ័តកម្មសម្រាប់ ៖* | | | | | |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | | 1,353,129 | 338,706 | 1,039,706 | 260,252 |
| ចំណូលបានពីជំនួយពន្យារ | | (2,292) | (574) | (3,056) | (765) |
| សំវិធានធនឥណទានអាក្រក់និងសង្ស័យ | | 320,251 | 80,163 | 411,695 | 103,053 |
| ខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | 5,727 | 1,434 | 23,018 | 5,762 |
| ចំណូលការប្រាក់សុទ្ធ | | (53,738,651) | (13,451,477) | (33,620,040) | (8,415,529) |
| | | (30,594,240) | (7,658,132) | (21,012,004) | (5,259,574) |
| *បម្រែបម្រួលក្នុងដើមទុនបង្វិល* | | | | | |
| សមតុល្យជាមួយធនាគារ | | (6,902,478) | (1,727,779) | (685,753) | (171,653) |
| សមតុល្យជាមួយធនាគារកណ្តាល | | (9,787,750) | (2,450,000) | 950,970 | 238,040 |
| ឥណទានអតិថិជន | | (106,300,505) | (26,608,387) | (59,652,877) | (14,931,884) |
| ទ្រព្យសកម្មផ្សេងៗ | | (843,597) | (211,162) | (403,307) | (100,953) |
| ប្រាក់បញ្ញើមានកាលកំណត់ | | (155,478) | (38,918) | (136,978) | (34,287) |
| បំណុលផ្សេងៗ | | 2,315,663 | 579,640 | 5,387,500 | 1,348,561 |
| សាច់ប្រាក់បានប្រើក្នុងប្រតិបត្តិការ | | (152,268,385) | (38,114,738) | (75,552,449) | (18,911,750) |
| ចំណូលការប្រាក់បានទទួល | | 74,306,293 | 18,599,823 | 49,073,643 | 12,283,766 |
| ចំណាយការប្រាក់បានបង់ | | (23,439,894) | (5,867,308) | (17,363,975) | (4,346,427) |
| ពន្ធលើប្រាក់ចំណេញបានបង់ | | (2,457,410) | (615,122) | (1,771,639) | (443,464) |
| សាច់ប្រាក់បានប្រើក្នុងសកម្មភាពប្រតិបត្តិការ | | (103,859,396) | (25,997,345) | (45,614,420) | (11,417,875) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់បញ្ញើបម្រុងជាមួយធនាគារកណ្តាល | | (559,590) | (140,073) | (300,000) | (75,094) |
| ទិញទ្រព្យសម្បត្តិ និងបរិក្ខារ | | (2,171,178) | (543,474) | (1,903,234) | (476,404) |
| ទិញកម្មវិធីកុំព្យូទ័រ | | - | - | (29,731) | (7,442) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | 2,533 | 634 | - | - |
| ការវិនិយោគ | | - | - | 660 | 165 |
| សាច់ប្រាក់បានប្រើក្នុងសកម្មភាពវិនិយោគ | | (2,728,235) | (682,913) | (2,232,305) | (558,775) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ប្រាក់បានពីប្រាក់កម្ចី | | 198,568,364 | 49,704,221 | 98,716,035 | 24,709,896 |
| សងប្រាក់កម្ចី | | (94,444,979) | (23,640,796) | (54,589,776) | (13,664,525) |
| ប្រាក់បានពីអនុបំណុល | | - | - | 4,064,000 | 1,017,272 |
| ប្រាក់បានពីការបន្ថែមដើមទុន | | 7,127,800 | 1,784,180 | - | - |
| ភាគលាភបានបង់ | 23 | (886,442) | (221,888) | (586,758) | (146,873) |
| សាច់ប្រាក់បានពីសកម្មភាពហិរញ្ញប្បទាន | | 110,364,743 | 27,625,717 | 47,603,501 | 11,915,770 |
| **កំណើន / (តំហាយ) សាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | **3,777,112** | **945,459** | **(243,224)** | **(60,880)** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមឆ្នាំ | | 24,103,115 | 6,033,321 | 24,346,339 | 6,027,814 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | 66,387 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងឆ្នាំ** | 24 | **27,880,227** | **6,978,780** | **24,103,115** | **6,033,321** |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី 10 ដល់ទំព័រទី 47 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**ធនាគារភូមិ (ខេមបូឌា) អិលធីឌី**

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2013

### 1. ព័ត៌មានទូទៅ

ធនាគារ ភូមិ (ខេមបូឌា) អិលធីឌី (ហៅកាត់ថា "ក្រុមហ៊ុន") ដែលមានអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតនៅកម្ពុជា នៅថ្ងៃទី 23 ខែ ឧសភា ឆ្នាំ 2002 ក្រោមការចុះបញ្ជីពាណិជ្ជកម្មលេខ Co. 1413/02E ដែលចេញដោយក្រសួងពាណិជ្ជកម្ម ។

ក្រុមហ៊ុន គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលបាន និងកំពុងបន្តសកម្មភាពចម្បងជាស្ថាប័នផ្តល់ឥណទានដល់ប្រជាជននៅតាមជនបទក្នុង 46 តំបន់ (ដែលមានសាខាចម្បងចំនួន 19 និងស្នាក់ការកណ្តាលនៅភ្នំពេញ) ។ គោលដៅចម្បងរបស់ក្រុមហ៊ុនគឺផ្តល់នូវសេវាមីក្រូហិរញ្ញវត្ថុដែលមានភាពជឿទុកចិត្ត និងអាចទទួលយកបានដល់សហគ្រិនខ្នាតតូច ក្នុងបណ្តាខេត្តក្រុងចំនួន 24 នៅក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារភូមិមាន ប្រតិបត្តិការនៅ 19 ខេត្តមានដូចជា តាកែវ កំពត បាត់ដំបង ស្វាយរៀង បន្ទាយមានជ័យ សៀមរាប កំពង់ចាម កណ្តាល ក្រចេះ កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ ព្រៃវែង ឧត្តរមានជ័យ កែប រតនគីរី ប៉ៃលិន ពោធិ៍សាត់ និងរាជធានីភ្នំពេញ។ សេវាកម្មហិរញ្ញវត្ថុ ត្រូវបានផ្តល់ឲ្យតាមរយៈធនាគារភូមិបានបង្កើតឡើងជាក្រុមសាមគ្គី ហើយក្រុមនីមួយៗ មានសមាជិកពី 2 ទៅ 7នាក់ ក៏ដូចជាផ្តល់ឲ្យតាមរយៈឯកត្តជនផងដែរ។

ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណរយៈពេល 3 ឆ្នាំដើម្បីធ្វើអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចាប់ពី ថ្ងៃទី 12 ខែ កុម្ភៈ ឆ្នាំ 2003 ដល់ថ្ងៃទី 12 ខែ កុម្ភៈ ឆ្នាំ 2006 ពីធនាគារជាតិនៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") ។ នៅថ្ងៃទី 20 ខែ មករា ឆ្នាំ 2006 ធនាគារជាតិនៃកម្ពុជាបានបន្តអាជ្ញាប័ណ្ណនេះសម្រាប់ រយៈពេល 3 ឆ្នាំ ទៀត ចាប់ពីថ្ងៃទី 12 ខែ កុម្ភៈ ឆ្នាំ 2006 ដល់ថ្ងៃទី 12 ខែ កុម្ភៈ ឆ្នាំ 2009 ។ នៅថ្ងៃទី 14 ខែ មករា ឆ្នាំ 2009 ក្រុមហ៊ុន បានទទួលអាជ្ញាប័ណ្ណជាអចិន្ត្រៃយ៍ពីធនាគារកណ្តាល ។

ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនមានទីតាំងនៅផ្ទះលេខ 94 ផ្លូវលេខ 360 សង្កាត់បឹងកេងកង 3 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

គិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2013 ក្រុមហ៊ុនមានបុគ្គលិកចំនួន 874 នាក់ (នៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2012 មានបុគ្គលិកចំនួន 695 នាក់) ។

ក្រុមប្រឹក្សាភិបាលបានអនុម័តឲ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនេះ នៅថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2014។

### 2. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញខាងក្រោម។ គោលការណ៍គណនេយ្យទាំងនេះ ត្រូវបានអនុវត្តយ៉ាងមានសង្គតភាពគ្រប់ឆ្នាំទាំងអស់ដែលបានបង្ហាញ លើកលែងតែមានបញ្ជាក់ផ្សេងពីនេះ។

#### 2.1 មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលត្រូវបានបង្ហាញជាប្រាក់រៀល (ហៅកាត់ថា "KHR") ត្រូវបានរៀបចំឡើងក្រោមការសន្មតថ្លៃដើម និងស្របទៅតាមស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS") និងគោលការណ៍ណែនាំរបស់ធនាគារកណ្តាល។

## 2. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.1 មូលដ្ឋាននៃការរៀបចំ (ត)

គោលការណ៍គណនេយ្យដែលបានប្រើប្រាស់អាចមានភាពខុសគ្នា ពីគោលការណ៍គណនេយ្យដែលត្រូវបានគេទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ។ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ ដោយអនុលោមទៅតាមយុត្តាធិការណាផ្សេងក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូចនេះរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ សម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលស្របទៅតាមស្តង់ដារគណនេយ្យកម្ពុជា តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មត ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងបំណុល និងការលាតត្រដាងទ្រព្យសកម្ម និងបំណុលយថាភាពដែលបានរាយការណ៍ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងប៉ះពាល់ដល់ចំនួននៃចំណូល និងចំណាយដែលបានរាយការណ៍នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ។ បើទោះជាការប៉ាន់ស្មានទាំងនេះ ផ្អែកទៅលើការយល់ដឹងដ៏សុក្រឹតបំផុតរបស់គណៈគ្រប់គ្រងទៅលើព្រឹត្តិការណ៍ និងសកម្មភាពផ្សេងៗនាពេលបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់លាក់ចុងក្រោយអាចខុសពីការប៉ាន់ស្មានទាំងនេះ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ 3 ។

### 2.2 ស្តង់ដារគណនេយ្យហិរញ្ញវត្ថុថ្មី

នៅថ្ងៃទី28 ខែសីហា ឆ្នាំ2009 ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានប្រកាសដាក់ឲ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទាំងស្រុងទៅតាមស្តង់ដារទាំងអស់ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ រួមទាំងបំណកស្រាយ និងវិសោធនកម្មពាក់ព័ន្ធផ្សេងៗដែលអាចកើតមានក្នុងកាលៈទេសៈនានាចំពោះស្តង់ដារនីមួយៗ ដោយការបន្ថែមពាក្យ "កម្ពុជា"។ អង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឲ្យស្របទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី1 ខែមករា ឆ្នាំ2012 ឬការិយ-បរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ។

យោងតាមសារាចរណែនាំលេខ 086 សហវ-កជគ ចុះថ្ងៃទី30 ខែកក្កដា ឆ្នាំ2012 ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុម័តឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ពន្យារពេលអនុវត្ត CIFRS រហូតដល់ការិយបរិច្ឆេទដែលចាប់ផ្តើមនៅថ្ងៃទី01 ខែមករា ឆ្នាំ2016។

របាយការណ៍ហិរញ្ញវត្ថុដំបូងរបស់ក្រុមហ៊ុន ដែលនឹងត្រូវរៀបចំតាម CIFRS គឺរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016។ ស្តង់ដារគណនេយ្យដែលក្រុមហ៊ុនប្រើប្រាស់នាពេលបច្ចុប្បន្ន គឺ CAS មានភាពខុសគ្នាជាច្រើនផ្នែក បើធៀបនឹង CIFRS។ ដូចនេះការអនុវត្ត CIFRS នឹងបណ្តាលឲ្យមានផលប៉ះពាល់ខ្លះលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## 2. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.3 ការប្តូររូបិយប័ណ្ណ

*ក. រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ*

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បង ដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ ក្រុមហ៊ុនថែរក្សាកំណត់ត្រាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាប្រាក់រៀលខ្មែរ ដែលជារូបិយប័ណ្ណចម្បងរបស់ក្រុមហ៊ុន។ ការកំណត់យកប្រាក់រៀលខ្មែរជារូបិយប័ណ្ណគោលរបស់ក្រុមហ៊ុន ដោយសារប្រាក់រៀលខ្មែរមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការរបស់ក្រុមហ៊ុន។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់រៀលខ្មែរ ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ក្រុមហ៊ុន។

*ខ. ប្រតិបត្តិការ និងសមតុល្យ*

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀលខ្មែរ ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់រៀលខ្មែរ តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណ ដែលបណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានាដែលកំណត់ជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់រៀលខ្មែរ តាមអត្រាប្តូរនាដំណាច់ឆ្នាំ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

អត្រាគោលដែលបានប្រើដើម្បីកត់ត្រារូបិយវត្ថុទ្រព្យសកម្ម និងបំណុលដែលជារូបិយប័ណ្ណផ្សេងៗ ប្តូរទៅជាប្រាក់រៀល គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការគឺ ៖

| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2013 | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2012 |
|---|---|---|
| ដុល្លារអាមេរិក ("US$") | 3,995 | 3,995 |
| បាតថៃ ("THB") | 122.5 | 131.0 |

តួលេខដែលត្រូវបានប្តូរនេះមិនត្រូវបានធ្វើសវនកម្មទេ ហើយមិនគួរបកស្រាយថាតួលេខនេះជាតួលេខសម្រាប់បង្ហាញដូចតួលេខជាប្រាក់រៀលនោះទេ ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់រៀល តាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។

### 2.4 មូលដ្ឋាននៃការសរុបរួម

របាយការណ៍ហិរញ្ញវត្ថុនេះ រួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ទីស្នាក់ការកណ្តាល និងរបាយការ-ណ៍ហិរញ្ញវត្ថុរបស់បណ្តាសាខានានា ក្រោយពីលុបចោលនូវរាល់សមតុល្យ និងប្រតិបត្តិការអន្តរសាខាសំខាន់ៗ។

### 2.5 សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យគ្មានកម្រិតនៅធនាគារកណ្តាល ប្រាក់បញ្ញើនៅធនាគារ ការវិនិយោគសាច់ប្រាក់ងាយស្រួលរយៈពេលខ្លី ដែលមានកាលកំណត់ដើមរយៈពេលបីខែឬតិចជាង គិតចាប់ពីថ្ងៃដែលក្រុមហ៊ុនមានលទ្ធភាពពេញលេញ ក្នុងការដកសាច់ប្រាក់នោះមកប្រើប្រាស់តាមតម្រូវការទូទៅ។

ឥណទានវិបារូបន៍ ត្រូវបានបង្ហាញនៅក្នុងបំណុលលើតារាងតុល្យការ។

## 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.6 ឥណទានអតិថិជន

ឥណទានអតិថិជន ត្រូវបានរាយការណ៍ក្នុងតារាងតុល្យការតាមចំនួនទឹកប្រាក់ដើម ដកចំនួនដែលបានជម្រះចេញពីបញ្ជី និងសំវិធានធនឥណទានអាក្រក់និងសង្ស័យ។

ឥណទានត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលមិនមានភាពប្រាកដប្រជាថានឹងអាចប្រមូលប្រាក់មកវិញបាន។ ឥណទានអតិថិជនដែលបានជម្រះចេញពីបញ្ជីរួច ហើយប្រមូលបានមកវិញ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

### 2.7 សំវិធានធនឥណទានអាក្រក់ និងសង្ស័យ

ភាពគ្រប់គ្រាន់នៃសំវិធានធនឥណទានអាក្រក់ និងសង្ស័យ ត្រូវបានគណនាជារៀងរាល់ខែ ដោយគណៈគ្រប់គ្រង។

ក្រុមហ៊ុនបានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន តាមតម្រូវការរបស់ប្រកាសលេខធ7-02-186ប្រ.ក. ចុះថ្ងៃទី13 ខែកញ្ញា ឆ្នាំ2002។ ប្រកាសនេះ តម្រូវឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងឡាយ ធ្វើចំណាត់ថ្នាក់សំពៀតឥណទានរបស់ខ្លួនជាបួនថ្នាក់ដូចខាងក្រោម ហើយត្រូវប្រាកដថាកម្រិតអប្បបរមានៃសំវិធានធនជាក់លាក់ត្រូវបានកត់ត្រា។

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃផុតកំណត់ | សំវិធានធន |
|---|---|---|
| *ឥណទានរយៈពេលខ្លី (តិចជាង1ឆ្នាំ):* | | |
| ស្តង់ដារ | 0-29 ថ្ងៃ | 0% |
| ក្រោមស្តង់ដារ | 30-59 ថ្ងៃ | 10% |
| សង្ស័យ | 60-89 ថ្ងៃ | 30% |
| បាត់បង់ | លើសពី 90 ថ្ងៃឡើងទៅ | 100% |
| *ឥណទានរយៈពេលវែង (លើសពី1ឆ្នាំឡើងទៅ):* | | |
| ស្តង់ដារ | 0-29 ថ្ងៃ | 0% |
| ក្រោមស្តង់ដារ | 30-179 ថ្ងៃ | 10% |
| សង្ស័យ | 180-359 ថ្ងៃ | 30% |
| បាត់បង់ | លើសពី 360 ថ្ងៃឡើងទៅ | 100% |

សំវិធានធនជាក់លាក់ ត្រូវបានគណនាតាមភាគរយនៃឥណទាននៅសល់ នៅពេលដែលឥណទានត្រូវបានធ្វើចំណាត់ថ្នាក់ ហើយត្រូវបានកត់ត្រាជាចំណាយ នៅក្នុងរបាយការណ៍លទ្ធផល។

ក្រុមហ៊ុនកត់ត្រាសំវិធានធន100% សម្រាប់ឥណទានដែលផុតកាលកំណត់សង 30ថ្ងៃ ឬលើសពីនេះ។ ចំនួនសំវិធានធនដែលលើសកម្រិតតម្រូវដោយធនគារកណ្តាល ត្រូវបានបង្ហាញជាសំវិធានធនទូទៅ។

ឥណទានត្រូវបានជម្រះចេញនៅពេលដែលឥណទានទាំងនោះ មិនអាចប្រមូលមកវិញបាន។ ឥណទានដែលបានជម្រះចេញ ត្រូវបានកាត់ចេញពីឥណទានដែលនៅសល់ និងពីសំវិធានធនសម្រាប់ឥណទានបាត់បង់។

ការប្រមូលបានមកវិញនូវឥណទានដែលបានជម្រះចេញពីគ្រាមុន និងត្រូវបានកត់ត្រាជាចំណូលប្រតិបត្តិការ នៅក្នុងរបាយការណ៍លទ្ធផល។

## 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.8 ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានតក់ត្រាថ្លៃដើម ដករំលស់បង្គរ និងការខាតបង្គរដែលបណ្តាលមកពីការចុះថយតម្លៃ។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗ ក្នុងការនាំយកទ្រព្យសម្បត្តិនោះ មកកាន់ទីតាំងនិងលក្ខខណ្ឌចាំបាច់ ដើម្បីឲ្យវាអាចធ្វើប្រតិបត្តិការទៅតាមការគ្រោងទុករបស់គណៈគ្រប់គ្រង។

ចំណាយបន្តបន្ទាប់ផ្សេងៗ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យដាច់ដោយឡែក តាមការសមស្រប តែនៅពេលដែលមានភាពប្រាកដថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះនឹងហូរចូលមកក្នុងក្រុមហ៊ុន ហើយថ្លៃដើមនៃទ្រព្យនោះ អាចត្រូវបានវាស់វែងគួរឲ្យជឿជាក់បានតែប៉ុណ្ណោះ។ ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយ-ការណ៍លទ្ធផល ក្នុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង។

ការធ្វើរំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានរំលស់ថយចុះ និងតាមអត្រាប្រចាំឆ្នាំដូចខាងក្រោម ៖

| | |
|---|---|
| យានយន្ត | 25% |
| កុំព្យូទ័រ | 50% |
| គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ | 25% |

តម្លៃសំណល់និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មត្រូវបានត្រួតពិនិត្យ និងធ្វើនិយ័តកម្មតាមការសមស្រប ប្រសិនបើមានសញ្ញាណនៃការប្រែប្រួលជាសារវន្តណាមួយ ចាប់តាំងពីកាលបរិច្ឆេទរបាយការណ៍មុនមក។

តម្លៃយោងនៃទ្រព្យសកម្មណាមួយ ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបានរបស់វា ត្រូវបានកត់ត្រាបន្ថយភ្លាមឱ្យនៅត្រឹមតម្លៃប៉ាន់ស្មានដែលអាចស្រង់មកវិញបាន។

ចំណេញ ឬខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាលើការលក់ចេញនៃទ្រព្យនោះ។

ទ្រព្យសម្បត្តិ និងបរិក្ខារដែលបានធ្វើរំលស់សព្វគ្រប់ ត្រូវបានរក្សាទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ រហូតដល់ពេលដែលទ្រព្យនោះត្រូវបានលក់ចេញ ឬជម្រះចេញ។

### 2.9 ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ និងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍តាមថ្លៃដើម ដករំលស់បង្គរ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។ ទ្រព្យសកម្មអរូបី ត្រូវបានធ្វើរំលស់តាមមូលដ្ឋានរំលស់ថេរ តាមអត្រា 50% ក្នុងមួយឆ្នាំ។

ចំណាយនានាពាក់ព័ន្ធនឹងការថែរក្សាកម្មវិធីកុំព្យូទ័រ ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលប្រតិបត្តិ-ការនោះបានកើតឡើង។

## 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.10 ការថយចុះតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានធ្វើរំលស់ទេ និងត្រូវបានត្រួតពិនិត្យប្រចាំឆ្នាំ រកការថយចុះតម្លៃរបស់វា។ ទ្រព្យសកម្មទាំងឡាយណាដែលត្រូវគេធ្វើរំលស់ ត្រូវបានគេត្រួតពិនិត្យរកការថយចុះតម្លៃរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថាតម្លៃយោងរបស់វា នឹងមិនអាចស្រង់មកវិញបាន។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាតាមចំនួនលម្អៀងរវាងតម្លៃយោងនៃទ្រព្យនោះ ធៀបជាមួយតម្លៃដែលអាចយកមកវិញបាន។ តម្លៃដែលអាចយកមកវិញបានគឺជាតម្លៃមួយណាដែលខ្ពស់ជាងគេ រវាងតម្លៃសមរម្យនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ និងតម្លៃនៅប្រើប្រាស់។ ក្នុងការវាយតម្លៃដើម្បីរកការថយចុះ ទ្រព្យសម្បត្តិទាំងឡាយត្រូវបានបែងចែកជាក្រុមតូចៗបំផុត ដើម្បីកំណត់ពីលំហូរសាច់ប្រាក់របស់វានីមួយៗ (ឯកតាបង្កើតសាច់ប្រាក់)។

### 2.11 ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានកត់ត្រាតាមចំនួនប្រាក់ដើម ដែលមិនទាន់ទូទាត់។ សោហ៊ុយផ្សេងៗដែលបានចំណាយដើម្បីទទួលបានប្រាក់កម្ចី ត្រូវបានធ្វើរំលស់លើមូលដ្ឋានរំលស់ថេរលើរយៈពេលនៃប្រាក់កម្ចី ទៅក្នុងរបាយការណ៍លទ្ធផល។

### 2.12 អនុបំណុល

អនុបំណុលត្រូវបានចាត់ទុកជាផ្នែកមួយនៃបំណុលហិរញ្ញវត្ថុ នៅពេលដែលមានកាតព្វកិច្ចតាមកិច្ចសន្យាដើម្បីប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុទៅឲ្យអង្គភាពមួយផ្សេងទៀត ឬដើម្បីផ្តោះប្តូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាមួយអង្គភាពមួយផ្សេងទៀត ក្រោមលក្ខខណ្ឌដែលមិនសូវអំណោយផលចំពោះក្រុមហ៊ុន ហើយប្រសិនបើវាមានភាពអំណោយផលចំពោះក្រុមហ៊ុន វានឹងត្រូវចាត់ទុកជាមូលធន។ អនុបំណុលដែលបានអនុម័តដោយធនាគារកណ្តាល ត្រូវបានរាប់បញ្ចូលទៅក្នុងដើមទុនថ្នាក់ទី2 ក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ក្រុមហ៊ុន អនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល។

### 2.13 សំវិធានធន

សំវិធានធនត្រូវបានកត់ត្រានៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោល ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាអាចតម្រូវឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឱ្យជឿជាក់បាន។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចនោះទាំងមូល។ សំវិធានធនត្រូវបានកត់ត្រាទោះបីជាកម្រិតលំហូរចេញនៃខ្ទង់ណាមួយនៅក្នុងចំណាត់ថ្នាក់កាតព្វកិច្ចដូចគ្នានោះ មានចំនួនតូចក៏ដោយ។

សំវិធានធនត្រូវបានវាស់វែងឡើងវិញតាមតម្លៃបច្ចុប្បន្ន នៃចំណាយដែលរំពឹងថាត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់។

## 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.14 ការកត់ត្រាចំណូល និងចំណាយការប្រាក់

ចំណូលការប្រាក់បានមកពីឥណទានអតិថិជន សមតុល្យនៅធនាគារកណ្តាល និងសមតុល្យនៅធនាគារ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ។ នៅពេលដែលឥណទានអតិថិជនក្លាយជាឥណទានមិនដំណើរការ ការកត់ត្រាចំណូលការប្រាក់ពីឥណទានអតិថិជន ត្រូវបានព្យួរទុកមួយរយៈរហូតដល់ពេលដែលទទួលបានសាច់ប្រាក់ជាក់ស្តែង។

ចំណាយការប្រាក់លើប្រាក់កម្ចី និងអនុបំណុល ត្រូវបានកត់ត្រាលើមូលដ្ឋានបង្គរ។

### 2.15 ភតិសន្យា

ភតិសន្យាដែលភាគីម្ចាស់ទ្រព្យនៅមានហានិភ័យជាក់លាក់ និងផលកម្មសិទ្ធិលើទ្រព្យនេះ ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ការទូទាត់ភតិសន្យាប្រតិបត្តិ (កាត់កងនឹងការលើកទឹកចិត្តផ្សេងៗ ដែលទទួលបានពីភាគីម្ចាស់ទ្រព្យ) ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផលតាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យា។

### 2.16 ប្រតិបត្តិការភាគីពាក់ព័ន្ធ

ភាគីដែលត្រូវបានចាត់ទុកថាមានការពាក់ព័ន្ធ ប្រសិនបើភាគីនោះមានលទ្ធភាពដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ក្នុងការគ្រប់គ្រងភាគីមួយផ្សេងទៀត ឬមានឥទ្ធិពលជាសារវន្តលើភាគីមួយផ្សេងទៀតក្នុងការសម្រេចចិត្តលើផ្នែកប្រតិបត្តិការ និងហិរញ្ញវត្ថុ ឬប្រសិនបើក្រុមហ៊ុននិងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួម ឬស្ថិតនៅក្រោមឥទ្ធិពលរួមរបស់ក្រុមហ៊ុនមេតែមួយ។ ភាគីពាក់ព័ន្ធអាចជាឯកបុគ្គលឬជាក្រុមហ៊ុន រាប់ទាំងសមាជិកគ្រួសារជិតដិតរបស់បុគ្គលនោះក៏ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធដែរ។

អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ភាគីពាក់ព័ន្ធត្រូវបានឲ្យនិយមន័យថាជាភាគីទាំងឡាយណាដែលកាន់កាប់ដោយផ្ទាល់ឬដោយប្រយោល យ៉ាងហោចណាស់10%នៃដើមទុនរបស់ក្រុមហ៊ុន ឬមានសិទ្ធិបោះឆ្នោត រួមទាំងឯកបុគ្គលដែលមានតួនាទីក្នុងអភិបាលកិច្ច ការដឹកនាំ ការគ្រប់គ្រង ឬ ការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន។

### 2.17 ពន្ធពន្យារលើប្រាក់ចំណេញ

បន្ទុកពន្ធលើប្រាក់ចំណេញក្នុងគ្រា ត្រូវបានគណនាតាមមូលដ្ឋានច្បាប់ពន្ធដារ ដែលបានអនុម័តរួចជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទរបាយការណ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ជាទីកន្លែងដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណេញជាប់ពន្ធ។

ពន្ធពន្យារត្រូវបានគណនាដោយប្រើវិធីសាស្ត្របំណុលក្នុងតារាងតុល្យការ លើលម្អៀងបណ្តោះអាសន្ននៃតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ធៀបនឹងចំនួនដែលបានប្រើប្រាស់ សម្រាប់ការគណនាពន្ធ ។ ពន្ធពន្យារត្រូវបានវាស់វែងតាមអត្រាពន្ធដែលរំពឹងថា នឹងត្រូវអនុវត្តលើលម្អៀងបណ្តោះអាសន្ននៅពេលដែលកត់ត្រាត្រឡប់ចូលមកវិញ ដោយផ្អែកតាមពន្ធដែលបានអនុម័តរួចជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទរបាយការណ៍។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានគេកាត់កងជាមួយនឹងពន្ធពន្យារបំណុល ប្រសិនបើក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីទូទាត់បំណុលពន្ធ និងពន្ធទ្រព្យសកម្មក្នុងឆ្នាំ ហើយប្រសិនបើវាទាក់ទងនឹងពន្ធលើប្រាក់ចំណេញដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ទៅលើអង្គភាពជាប់ពន្ធតែមួយ។

## 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.17 ពន្ធពន្យារលើប្រាក់ចំណេញ (ត)

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា លុះត្រាតែមានភាពប្រាកដថាក្រុមហ៊ុននឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត សម្រាប់យកលម្អៀងបណ្តោះអាសន្នមកប្រើប្រាស់។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់ការបរិច្ឆេទរបាយការណ៍នីមួយៗ ហើយត្រូវបានកត់ត្រាបន្ថយរហូតដល់កម្រិតមួយដែលមិនមានភាពប្រាកដថា នឹងមានអត្ថប្រយោជន៍ពន្ធពាក់ព័ន្ធនឹងត្រូវកើតឡើង។

### 2.18 ទុនបម្រុង

*(i) ទុនបម្រុងតាមច្បាប់*

អនុលោមតាមលក្ខន្តិកៈ ក្រុមហ៊ុនត្រូវផ្ទេរប្រាក់ចំណេញប្រចាំឆ្នាំរបស់ខ្លួនបន្ទាប់ពីកាត់កងការខាតក្នុងឆ្នាំមុនៗរួច ចំនួន5% ទៅក្នុងគណនីទុនបម្រុងតាមច្បាប់។ ការផ្ទេរនេះនឹងត្រូវបញ្ឈប់នៅពេលដែលទុនបម្រុងនេះកើនឡើងដល់10% នៃដើមទុនចុះបញ្ជីរបស់ក្រុមហ៊ុន។

*(ii) ទុនបម្រុងផ្សេងៗ*

យោងតាមកិច្ចព្រមព្រៀងឥណទានដែលបានចុះហត្ថលេខារវាង Instituto De Crédito Ofical (ICO) នៃព្រះរាជាណាចក្រអេស្ប៉ាញ និងក្រុមហ៊ុន ក្រុមហ៊ុនត្រូវបង្កើតនិងរក្សាមូលនិធិទុនបម្រុង សម្រាប់ការពង្រឹងដើមទុនដោយផ្ទេរប្រាក់ចំណេញប្រចាំឆ្នាំនីមួយៗរបស់ខ្លួននូវចំនួនដែលសមមូលនឹង 3.5% នៃ ចំនួនប្រាក់ដើមឥណទានដែលនៅមិនទាន់ទូទាត់។ ទុនបម្រុងផ្សេងៗនេះ គឺសម្រាប់ពង្រីកស្ថាប័ន និងត្រូវបានរក្សាទុកនៅក្នុងគណនីទុនបម្រុងផ្សេងៗ ទៅតាមអាយុកាលឥណទាន ឬបើមិនដូច្នោះ ត្រូវមានការយល់ព្រមពី ICO ។

### 2.19 ភាគលាភ

ភាគលាភត្រូវបានកត់ត្រាក្នុងមូលធននៅក្នុងការិយបរិច្ឆេទដែលភាគលាភត្រូវបានអនុម័តដោយភាគទុនិករបស់ក្រុមហ៊ុន។

ភាគលាភសម្រាប់ឆ្នាំដែលបានប្រកាសក្រោយកាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ស្តីពីព្រឹត្តការណ៍ក្រោយតារាងតុល្យការ។

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2013**

## 3. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាមុន និងកត្តាផ្សេងៗទៀត រួមមានការរំពឹងទុកនៃព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។ ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ដោយគិតទៅលើអនាគតកាល។ តាមនិយមន័យលទ្ធផលនៃការប៉ាន់ស្មានគណនេយ្យ កម្រស្មើគ្នានឹងលទ្ធផលជាក់ស្តែងណាស់។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដែលមានហានិភ័យជាសារវន្តបណ្តាលឱ្យមាននិយ័តកម្មធំដុំទៅលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងឆ្នាំបន្ទាប់ ត្រូវបានពិភាក្សាដូចខាងក្រោម ៖

### 3.1 សំវិធានធនឥណទានអាក្រក់ និងសង្ស័យ

ក្រុមហ៊ុនអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន តាមតម្រូវការរបស់ប្រកាសលេខ ធ7-02-186ប្រ.ក. ចុះថ្ងៃទី13 ខែកញ្ញា ឆ្នាំ2002។ ធនាគារកណ្តាលតម្រូវឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងឡាយធ្វើចំណាត់ថ្នាក់សំពៀតឥណទានរបស់ខ្លួនជាបួនថ្នាក់ ហើយត្រូវប្រាកដថាកម្រិតអប្បបរមានៃសំវិធានធនជាក់លាក់ ត្រូវបានកត់ត្រាអាស្រ័យទៅតាមការធ្វើចំណាត់ថ្នាក់ពាក់ព័ន្ធ។ ក្នុងការធ្វើចំណាត់ថ្នាក់ឥណទានតម្រូវឱ្យក្រុមហ៊ុនគិតពិចារណាទៅលើប្រវត្តិនៃការសងប្រាក់ និងលក្ខខណ្ឌហិរញ្ញវត្ថុរបស់អ្នកខ្ចីប្រាក់។

ក្រុមហ៊ុនកត់ត្រាសំវិធានធន 100% សម្រាប់ឥណទានខាតបង់ដែលផុតកាលកំណត់សង 30ថ្ងៃ ។ ចំនួនសំវិធានធនដែលលើសកម្រិតតម្រូវដោយធនគារកណ្តាល ត្រូវបានបង្ហាញជាសំវិធានធនបន្ថែម។

### 3.2 ពន្ធលើប្រាក់ចំណេញ

ពន្ធត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ននៃបទប្បញ្ញត្តិពន្ធដារ ប៉ុន្តែបទប្បញ្ញត្តិទាំងអស់នេះមានការផ្លាស់ប្តូរពីមួយគ្រាទៅមួយគ្រា ហើយការសម្រេចជាចុងក្រោយលើចំនួនពន្ធ នឹងធ្វើឡើងបន្ទាប់ពីអធិការកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយ ខុសគ្នាពីចំនួនដែលបានកត់ត្រាពីដំបូង នោះភាពលម្អៀងនេះនឹងធ្វើឱ្យប៉ះពាល់ដល់ពន្ធលើប្រាក់ចំណេញ និងសំវិធានធនពន្ធពន្យារនៅក្នុងឆ្នាំដែលការកំណត់ពន្ធបានធ្វើឡើង។

### 3.3 រូបិយប័ណ្ណគោល

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ខ្មែររៀលបង្ហាញពីផលប៉ះពាល់សេដ្ឋកិច្ចនៃមូលដ្ឋានប្រតិបត្តិការ ព្រឹត្ត-ការណ៍ និងលក្ខខណ្ឌផ្សេងៗ។ ខ្មែររៀលគឺជារូបិយប័ណ្ណដែលក្រុមហ៊ុនវាស់វែងប្រតិបត្តិការរបស់ខ្លួន និងរាយការណ៍ពីលទ្ធផលរបស់ខ្លួន ក៏ដូចជារូបិយប័ណ្ណដែលទទួលបានពីភាគទុនិក និង បង់ភាគលាភទៅឲ្យភាគទុនិករបស់ខ្លួនផងដែរ។ ខ្មែររៀល គឺជារូបិយប័ណ្ណរបស់កម្ពុជា។

## 4. សាច់ប្រាក់ក្នុងដៃ

| | 2013 | | 2012 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ការិយាល័យកណ្តាល | 2,000 | 501 | 2,000 | 501 |
| សាខានានា | 1,322,774 | 331,107 | 937,095 | 234,567 |
| | 1,324,774 | 331,608 | 939,095 | 235,068 |

## 5. សមតុល្យនៅធនាគារកណ្តាល

| | 2013 | | 2012 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| គណនីចរន្ត | 4,421,771 | 1,106,826 | 8,757,156 | 2,192,029 |
| ប្រាក់បញ្ញើមានកំណត់ (i) | 12,983,750 | 3,250,000 | 3,196,000 | 800,000 |
| ប្រាក់បញ្ញើតាមច្បាប់ (ii) | 1,168,410 | 292,468 | 608,820 | 152,395 |
| ប្រាក់តម្កល់ធានាដើមទុន (ii) | 15,200 | 3,805 | 15,200 | 3,805 |
| | 18,589,131 | 4,653,099 | 12,577,176 | 3,148,229 |

(i) ប្រាក់បញ្ញើមានកាលកំណត់រយៈពេល 6ខែ នៅធនាគារកណ្តាល ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំក្នុងចន្លោះពី 0.17% ទៅ 0.19% ក្នុងមួយឆ្នាំ។

(ii) អនុលោមតាមប្រកាសរបស់ធនាគារកណ្តាល លេខ ធ700-006 ប្រ.ក ស្តីពីការផ្តល់អជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនបានថែរក្សាប្រាក់តម្កល់ធានាដើមទុនអបប្បរមាស្មើនឹង 5% នៃដើមទុនរបស់ខ្លួន គិតជាប្រាក់រៀលស្មើនឹង 23,368,200 ពាន់រៀល គិតត្រឹមថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2013 នៅក្នុងគណនីមានការប្រាក់នៅធនាគារកណ្តាល (គណនីនេះ ទទួលបានអត្រាការប្រាក់ 3% ក្នុងមួយឆ្នាំ យោងតាមប្រកាសរបស់ធនាគារកណ្តាលលេខ 06.210 ប្រ.ក) ។

(ii) (iii) យោងតាមប្រកាសលេខ ធ702-45 តម្រូវឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណទាំងអស់ ត្រូវតម្កល់ ប្រាក់បញ្ញើ 5% នៃប្រាក់បញ្ញើសរុបរបស់ខ្លួននៅក្នុងគណនីនៅធនាគារកណ្តាល។ ទុនបម្រុងកាតព្វកិច្ចនេះ មិនមានការប្រាក់ទេ។

## 6. សមតុល្យនៅធនាគារផ្សេងៗ

| | 2013 | | 2012 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| គណនីចរន្ត | 7,390,456 | 1,849,927 | 2,613,425 | 654,173 |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | 30,468,677 | 7,626,703 | 25,365,120 | 6,349,217 |
| គណនីសន្សំ | 11,058,532 | 2,768,092 | 4,387,265 | 1,098,189 |
| | 48,917,665 | 12,244,722 | 32,365,810 | 8,101,579 |

គណនីចរន្តមិនទទួលបានការប្រាក់ទេ។ អត្រាការប្រាក់ប្រចាំឆ្នាំ នៃគណនីប្រាក់បញ្ញើមានកាលកំណត់ និងគណនីសន្សំ មានចន្លោះពី 0.50% ទៅ 4.75% ក្នុងមួយឆ្នាំ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2012 ៖ 0.50% ទៅ 4.75%) ។

## 7. ឥណទានអតិថិជន

| | 2013 | | 2012 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានធនាគារភូមិ | | | | |
| ឥណទានបញ្ចប់វគ្គ | 103,560,276 | 25,922,472 | 71,414,811 | 17,876,048 |
| ឥណទានក្រុមសាមគ្គី | | | | |
| ឥណទានមានកាលកំណត់ | 28,096,247 | 7,032,853 | 21,270,627 | 5,324,312 |
| ឥណទានឯកត្តជន | | | | |
| ឥណទានមានកាលកំណត់ | 123,278,831 | 30,858,281 | 76,162,697 | 19,064,505 |
| ឥណទានបញ្ចប់វគ្គ | 41,877,611 | 10,482,506 | 23,159,936 | 5,797,231 |
| ឥណទានបុគ្គលិក | 2,598,469 | 650,430 | 1,360,932 | 340,659 |
| | 299,411,434 | 74,946,542 | 193,369,003 | 48,402,755 |
| សំវិធានធនឥណទានអាក្រក់ និងសង្ស័យ | | | | |
| សំវិធានធនជាក់លាក់ | (259,684) | (65,002) | (178,339) | (44,641) |
| សំវិធានធនទូទៅ | (186,451) | (46,672) | (205,619) | (51,469) |
| | (446,135) | (111,674) | (383,958) | (96,110) |
| ឥណទានអតិថិជនសុទ្ធ | 298,965,299 | 74,834,868 | 192,985,045 | 48,306,645 |

## 7. ឥណទានអតិថិជន (ត)

បម្រែបម្រួលសំវិធានធនឥណទានអតិថិជនអាក្រក់ និងសង្ស័យមានដូចខាងក្រោម៖

| | 2013 | | 2012 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| សំវិធានធនដើមឆ្នាំ | 383,958 | 96,110 | 170,503 | 42,214 |
| សំវិធានធនក្នុងឆ្នាំ | 320,251 | 80,163 | 411,695 | 103,053 |
| បំណុលអាក្រក់បានជម្រះចេញពីបញ្ជី | (255,695) | (64,004) | (196,714) | (49,240) |
| ចំណេញពីការប្តូររូបិយប័ណ្ណ | (2,379) | (595) | (1,526) | (382) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 465 |
| ដំណាច់ឆ្នាំ | 446,135 | 111,674 | 383,958 | 96,110 |

ឥណទានអតិថិជនត្រូវបានវិភាគដូចខាងក្រោម៖

### (ក) វិភាគតាមវិស័យសេដ្ឋកិច្ច

| | 2013 | | 2012 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| កសិកម្ម | 166,138,444 | 41,586,594 | 109,127,452 | 27,316,009 |
| ជំនួញ និងពាណិជ្ជកម្ម | 49,440,466 | 12,375,586 | 33,275,757 | 8,329,351 |
| សេវាកម្ម | 26,488,312 | 6,630,366 | 17,676,038 | 4,424,540 |
| ផ្ទះ/គ្រួសារ | 48,533,202 | 12,148,486 | 25,231,106 | 6,315,671 |
| សំណង់ | 2,758,293 | 690,436 | 2,874,298 | 719,474 |
| ការដឹកជញ្ជូន | 566,828 | 141,884 | 929,664 | 232,707 |
| វិស័យផ្សេងៗ | 5,485,889 | 1,373,190 | 4,254,688 | 1,065,003 |
| | 299,411,434 | 74,946,542 | 193,369,003 | 48,402,755 |

### (ខ) វិភាគតាមស្ថានភាពនិវេសនដ្ឋាន

| | 2013 | | 2012 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| និវេសនដ្ឋាន | 299,411,434 | 74,946,542 | 193,369,003 | 48,402,755 |

ធនាគារភូមិ (ខេមបូឌា) អិលធីឌី

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2013

## 7. ឥណទានអតិថិជន (ត)

### (គ) វិភាគតាមទំនាក់ទំនង

| | 2013 | | 2012 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| អតិថិជន | 296,812,965 | 74,296,112 | 192,008,071 | 48,062,096 |
| ឥណទានបុគ្គលិក | 2,598,469 | 650,430 | 1,360,932 | 340,659 |
| | 299,411,434 | 74,946,542 | 193,369,003 | 48,402,755 |

### (ឃ) វិភាគតាមទីតាំង

| | 2013 | | 2012 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ការិយាល័យកណ្តាល | 563,836 | 141,135 | 223,190 | 55,867 |
| សាខា៖ | | | | |
| ខេត្តបន្ទាយមានជ័យ | 11,200,433 | 2,803,613 | 8,899,675 | 2,227,706 |
| ស្រុកបាវាយ | 2,560,879 | 641,021 | - | - |
| ស្រុកបាទី | 10,426,188 | 2,609,809 | 7,817,429 | 1,956,803 |
| ខេត្តបាត់ដំបង | 21,150,985 | 5,294,364 | 13,661,324 | 3,419,606 |
| ស្រុកឈូក | 16,081,199 | 4,025,332 | 11,826,972 | 2,960,444 |
| ខេត្តកំពង់ចាម | 15,063,768 | 3,770,655 | 10,993,481 | 2,751,810 |
| ខេត្តកំពង់ស្ពឺ | 5,311,617 | 1,329,566 | 2,201,353 | 551,027 |
| ស្រុកកំពង់ត្របែក | 7,984,887 | 1,998,720 | 5,904,955 | 1,478,086 |
| ស្រុកកំរៀង | 5,134,979 | 1,285,352 | - | - |
| ខេត្តកណ្តាល | 16,735,723 | 4,189,167 | 11,582,477 | 2,899,243 |
| ខេត្តក្រចេះ | 16,017,240 | 4,009,322 | 12,795,591 | 3,202,901 |
| ខេត្តឧត្តរមានជ័យ | 15,439,576 | 3,864,725 | 7,715,281 | 1,931,234 |
| ស្រុកឧត្តុង្គ | 5,811,663 | 1,454,734 | 3,675,011 | 919,903 |
| ស្រុកអូរាំងឪ | 5,252,965 | 1,314,885 | 2,787,133 | 697,655 |
| ស្រុកពាមរក៍ | 2,850,008 | 713,394 | - | - |
| រាជធានីភ្នំពេញ | 7,821,087 | 1,957,719 | 7,449,791 | 1,864,779 |
| ក្រុងប៉ោយប៉ែត | 14,145,745 | 3,540,862 | 10,833,814 | 2,711,843 |
| ស្រុកព្រែកប្បាស | 13,084,764 | 3,275,285 | 8,079,776 | 2,022,472 |
| ខេត្តព្រៃវែង | 4,101,396 | 1,026,632 | 2,350,468 | 588,352 |
| ស្រុកពារាំង | 822,049 | 205,770 | - | - |
| ខេត្តពោធិ៍សាត់ | 387,993 | 97,120 | - | - |
| ខេត្តរតនគីរី | 2,892,357 | 723,994 | - | - |

## 7. ឥណទាននិងបុរេប្រទានអតិថិជន (ត)

### (ឃ) វិភាគតាមទីតាំង (ត)

| | 2013 | | 2012 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ស្រុករតនមណ្ឌល | 14,780,070 | 3,699,642 | 9,539,905 | 2,387,961 |
| ស្រុករមាសហែក | 8,361,262 | 2,092,932 | 6,456,405 | 1,616,121 |
| ខេត្តសៀមរាប | 34,382,457 | 8,606,372 | 21,493,066 | 5,379,991 |
| ក្រុងសូង | 10,347,565 | 2,590,129 | 6,244,141 | 1,562,989 |
| ខេត្តស្វាយរៀង | 13,033,717 | 3,262,507 | 9,062,091 | 2,268,359 |
| ស្រុកត្រាំកក់ | 17,665,026 | 4,421,784 | 11,775,674 | 2,947,603 |
| | 299,411,434 | 74,946,542 | 193,369,003 | 48,402,755 |

### (ង) វិភាគតាមចំណាត់ថ្នាក់

| | 2013 | | 2012 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានស្តង់ដារ | | | | |
| មានការធានា | 167,485,933 | 41,923,888 | 100,413,833 | 25,134,877 |
| មិនមានការធានា | 131,479,366 | 32,910,980 | 92,571,212 | 23,171,768 |
| ឥណទានក្រោមស្តង់ដារ | | | | |
| មានការធានា | 54,577 | 13,661 | 124,332 | 31,122 |
| មិនមានការធានា | 44,944 | 11,250 | 19,867 | 4,973 |
| ឥណទានសង្ស័យ | | | | |
| មានការធានា | 111,403 | 27,886 | 78,134 | 19,558 |
| មិនមានការធានា | 27,000 | 6,758 | 30,208 | 7,561 |
| ឥណទានបាត់បង់ | | | | |
| មានការធានា | 102,997 | 25,782 | 67,266 | 16,838 |
| មិនមានការធានា | 105,214 | 26,337 | 64,151 | 16,058 |
| | 299,411,434 | 74,946,542 | 193,369,003 | 48,402,755 |

### (ឆ) វិភាគតាមអត្រាការប្រាក់ (ប្រចាំខែ)

អត្រាការប្រាក់ប្រចាំខែនៅក្នុងអំឡុងឆ្នាំប្រតិបត្តិការ មានដូចខាងក្រោម ៖

| | 2013 | 2012 |
|---|---|---|
| ឥណទានជារៀលខ្មែរ | 2.50% - 3.50% | 2.50% - 3.50% |
| ឥណទានជាដុល្លារអាមេរិក | 1.70% - 3.50% | 1.80% - 3.50% |
| ឥណទានជាបាតថៃ | 2.50% - 3.50% | 2.50% - 3.50% |

## 8. ទ្រព្យសកម្មផ្សេងៗ

| | 2013 | | 2012 | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| បង្គរការប្រាក់ត្រូវទទួល | 5,618,372 | 1,406,351 | 3,688,886 | 923,376 |
| ចំណាយបង់មុន | 1,792,344 | 448,647 | 1,289,510 | 322,781 |
| ផ្សេងៗ | 568,411 | 142,281 | 227,648 | 56,983 |
| | 7,979,127 | 1,997,279 | 5,206,044 | 1,303,140 |

## 9. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | គ្រឿងសង្ហារឹម និងបរិក្ខារ ការិយាល័យ ពាន់រៀល | យានយន្ត ពាន់រៀល | បរិក្ខារ កុំព្យូទ័រ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី01 ខែមករា 2012** | | | | |
| ថ្លៃដើម | 276,507 | 2,999,421 | 1,420,992 | 4,696,920 |
| រំលស់បង្គរ | (154,317) | (1,851,539) | (1,158,495) | (3,164,351) |
| តម្លៃចុះបញ្ជីសុទ្ធ | 122,190 | 1,147,882 | 262,497 | 1,532,569 |
| **ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2012** | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | 122,190 | 1,147,882 | 262,497 | 1,532,569 |
| ការទិញបន្ថែម | 170,695 | 1,323,013 | 409,526 | 1,903,234 |
| រំលស់ | (393) | (20,847) | (1,778) | (23,018) |
| ការលក់ចេញ | (73,130) | (612,845) | (335,161) | (1,021,136) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | 219,362 | 1,837,203 | 335,084 | 2,391,649 |
| **គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2012** | | | | |
| ថ្លៃដើម | 437,767 | 4,170,889 | 1,633,313 | 6,241,969 |
| រំលស់បង្គរ | (218,405) | (2,333,686) | (1,298,229) | (3,850,320) |
| តម្លៃចុះបញ្ជីសុទ្ធ | 219,362 | 1,837,203 | 335,084 | 2,391,649 |
| សមមូលនឹងដុល្លារអាមេរិក | 54,909 | 459,876 | 83,876 | 598,661 |
| **គិតត្រឹមថ្ងៃទី01 ខែមករា 2013** | | | | |
| ថ្លៃដើម | 437,767 | 4,170,889 | 1,633,313 | 6,241,969 |
| រំលស់បង្គរ | (218,405) | (2,333,686) | (1,298,229) | (3,850,320) |
| តម្លៃចុះបញ្ជីសុទ្ធ | 219,362 | 1,837,203 | 335,084 | 2,391,649 |

## 9. ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

| | គ្រឿងសង្ហារឹម និងបរិក្ខារ ការិយាល័យ ពាន់រៀល | យានយន្ត ពាន់រៀល | បរិក្ខារ កុំព្យូទ័រ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|
| **ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2013** | | | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | 219,362 | 1,837,203 | 335,084 | 2,391,649 |
| ការទិញបន្ថែម | 186,810 | 1,501,435 | 482,933 | 2,171,178 |
| ការលក់ចេញ | (1,828) | (4,840) | (1,592) | (8,260) |
| រំលស់ | 101,361 | 833,873 | 408,610 | 1,343,844 |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | 505,705 | 4,167,671 | 1,225,035 | 5,898,411 |
| | | | | |
| **គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2013** | | | | |
| ថ្លៃដើម | 617,648 | 5,665,120 | 2,040,554 | 8,323,322 |
| រំលស់បង្គរ | (314,665) | (3,165,195) | (1,632,739) | (5,112,599) |
| តម្លៃចុះបញ្ជីសុទ្ធ | 302,983 | 2,499,925 | 407,815 | 3,210,723 |
| សមមូលនឹងដុល្លារអាមេរិក | 75,841 | 625,763 | 102,081 | 803,685 |

## 10. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានថ្លៃដើមកម្មវិធីកុំព្យូទ័រ និងកម្រៃអាជ្ញាប័ណ្ណ មានដូចខាងក្រោម ៖

| | 2013 ពាន់រៀល | 2012 ពាន់រៀល |
|---|---|---|
| **គិតត្រឹមថ្ងៃទី01 ខែមករា** | | |
| ថ្លៃដើម | 190,298 | 160,567 |
| រំលស់បង្គរ | (171,728) | (153,158) |
| តម្លៃចុះបញ្ជីសុទ្ធ | 18,570 | 7,409 |
| | | |
| **ដំណាច់ឆ្នាំ** | | |
| តម្លៃចុះបញ្ជីសុទ្ធដើមគ្រា | 18,570 | 7,409 |
| ការទិញបន្ថែម | - | 29,731 |
| រំលស់ | (9,285) | (18,570) |
| តម្លៃចុះបញ្ជីសុទ្ធចុងគ្រា | 9,285 | 18,570 |
